# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

មហាអយ្យការ ប្រចាំ
សាលាឧទ្ធរណ៍ ភ្នំពេញ
លេខ ៤១៦/៩៧

# អគ្គរដ្ឋអាជ្ញា ប្រចាំសាលាឧទ្ធរណ៍ភ្នំពេញ

**ជម្រាបមក**

**គ្រប់លោកព្រះរាជអាជ្ញាប្រចាំតុលាការខេត្ត-ក្រុង និងយោធា**

**សូមជ្រាប។**

**កម្មវត្ថុ:** នយោបាយបង្ក្រាបជនល្មើសឱ្យបានតឹងតែង និងប្រសិទ្ធិភាព ។

**យោង:** បញ្ជារបស់សម្តេចនាយករដ្ឋមន្ត្រីទី២ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ខ្ញុំសូមរំលឹកអស់លោកព្រះរាជអាជ្ញាទូទាំងព្រះរាជាណាចក្រកម្ពុជាថា ក្នុងមួយរយៈពេលកន្លងមកនេះអំពើល្មើសព្រហ្មទណ្ឌគ្រប់បែបយ៉ាងមានភាពកើនឡើងប្រព្រឹត្តរបៀបអាណាធិបតេយ្យនៅគ្រប់ទិសទី ដែលជាអំពើទាក់ទាញអារម្មណ៍ មតិជាតិ និងអន្តរជាតិ ឱ្យយល់ឃើញថាអាជ្ញាធរមានសមត្ថកិច្ចរបស់យើងគ្មានមធ្យោបាយដើម្បីទប់ទល់ និងបង្ក្រាបឱ្យមានប្រសិទ្ធិភាព ។

អំពើដែលមានប្រព្រឹត្តកន្លងមកនោះ គឺអំពើប្លន់ សម្លាប់ អំពើចាប់មនុស្សជម្រិតទារយកប្រាក់ អំពើពង្រត់មនុស្ស ដើម្បីលក់ឱ្យធ្វើត្រីបេស្យា ។ ល ។ អំពើទាំងនេះអាចប្រព្រឹត្តទៅបានដោយសារជនល្មើសមានលទ្ធភាពប្រើប្រាស់អាវុធ ហើយអាវុធទាំងនេះជួនកាលជាអាវុធត្រឹមត្រូវតាមច្បាប់ មានលិខិតស្នាមត្រឹមត្រូវ ជួនកាលជាអាវុធ គ្មានលិខិតស្នាម ការប្រើប្រាស់ ឬទិសដៅប្រើប្រាស់មិនត្រឹមត្រូវតាមច្បាប់ ។ ប្រភពអាវុធគ្មានច្បាប់គេឃើញស្ថិតនៅកន្លែងទីផ្សារទឹកថ្លា ដែលជនជនល្មើសអាចទៅរកទិញបាន ជនល្មើសជាឈ្មួញអាចទិញ អាចលក់ និងអាចរក្សាជាសន្និធិ ស្តុក បានដោយគ្មានបារម្ភថាល្មើសនិងច្បាប់ ហើយមានទោសនោះសោះ ។ ម៉្យាងទៀតអាវុធដែលខុសច្បាប់ ជនល្មើសអាចស្វែងរកជនល្មើសក្លែងលិខិតបន្ថែមទៀត ដើម្បីមានលិខិតបញ្ជាក់អំពីភាពស្របច្បាប់ចំពោះមុខអាជ្ញាធរដែកឆេរ ឬចំពោះឈ្មួញបន្ត ឬអ្នកទិញប្រើប្រាស់បន្តបានដោយស្រួល ។ ចំណែកសម្បត្តិទ្រព្យបានមកពីអំពើល្មើសក៏ដូច្នេះដែរ ឧទាហរណ៍ ម៉ូតូ ឬរថយន្ត ដែលជាវត្ថុលើស ជនល្មើសអាចធ្វើលិខិតប័ណ្ណសម្គាល់យានយន្តក្លែងបានយ៉ាងឆាប់រហ័ស អាចរកឈ្មួញទិញ ឬដូរបានដោយស្រួល ដែលជាកត្តាជម្រុញបទលួច ប្លន់ ឱ្យកាន់តែរីកដុះដាលថែមទៀត ។

ខ្ញុំសង្កេតឃើញថា អំពើជួញដូរអាវុធ និងក្លែងលិខិតខាងលើ មិនសូវឃើញអយ្យការចោទប្រកាន់ជាបទល្មើស ហើយសុំឱ្យតុលាការកាត់ទោសសោះ ដែលជាភាពមួយឱ្យយល់ថាអំពើទាំងនេះមិនខុសនិងច្បាប់ទេ ប៉ុន្តែផ្ទុយទៅវិញអំពើទាំងនេះ ជាអំពើរក្សាអាវុធ កាន់កាប់អាវុធ ដែលមានចែងនឹងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥៤ នៃច្បាប់ព្រហ្មទណ្ឌ និងអំពើក្លែងលិខិតប័ណ្ណសម្គាល់យានយន្ត ជាអំពើក្លែងលិខិតសាធារណៈចែងក្នុងមាត្រា ៤៩ ច្បាប់ព្រហ្មទណ្ឌ ។ បន្ថែមទៅនឹងអំពើខាងលើ ខ្ញុំសូមរំលឹកថាមានអំពើត្រួតពិនិត្យតាមដងផ្លូវជាតិសាធារណៈ Controle ជជុះ ក៏ជាបទល្មើសព្រហ្មទណ្ឌដែរ ព្រោះថាបើអំពើនេះប្រព្រឹត្តដោយក្រុមត្រួតពិនិត្យមិនត្រឹមត្រូវជាអំពើប្លន់មាត្រា ៣៤ច្បាប់ព្រហ្មទណ្ឌ បើប្រព្រឹត្តដោយក្រុម Controle ត្រឹមត្រូវទៅលើកំហុសរបស់អ្នកដឹកជញ្ជូនជាអំពើទារសំណូកចែងក្នុងមាត្រា ៣៨ នៃច្បាប់ព្រហ្មទណ្ឌ ដូច្នេះត្រូវតែអយ្យការចាត់ការឱ្យមានប្រសិទ្ធិភាពទៅអនាគត ។

ខ្ញុំសូមរំលឹកថានៅពេលថ្មីៗនេះ សម្តេចនាយករដ្ឋមន្ត្រីទី២បានមានវិធានការណ៍ចាត់ការរៀបចំឱ្យមានរបៀបរៀបរយឡើងវិញ ដោយសុំឱ្យផ្តន្ទាទោសជនល្មើសបង្កើតបទល្មើសអាណាធិបតេយ្យទាំងនោះឱ្យបានតឹងរឹង ដើម្បីផ្តល់សុវត្ថិភាពជូនភ្ញៀវបេសកជនអន្តរជាតិ ជនអន្តោប្រវេសន៍ វិនិយោគទុន អនិកជន ភ្ញៀវទេសចរណ៍ និងប្រជាជនខ្មែរឱ្យបានពេញលេញ ហើយឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក៏មានសេចក្តីណែនាំសូមឱ្យតុលាការគ្រប់ជាន់ថ្នាក់មានវិធានការណ៍ផ្តន្ទាទោសជនល្មើសឱ្យបានតឹងរឹងដែរ ដូចលោកបានរៀបរាប់ក្នុងលិខិតថតចម្លងជូនភ្ជាប់មកជាមួយនេះ ។

ដូច្នេះខ្ញុំសូមលោកព្រះរាជអាជ្ញាប្រចាំតុលាការគ្រប់ខេត្ត.ក្រុង យកចិត្តទុកដាក់អនុវត្តច្បាប់ឱ្យបានហ្មត់ចត់ ចោទប្រកាន់ និងជូនខ្លួនជនល្មើសទៅតុលាការឱ្យបានគ្រប់បទល្មើស និងសន្និដ្ឋានសុំឱ្យតុលាការផ្តន្ទាទោសជនល្មើសឱ្យ បានតឹងតែងដូចចំណាររបស់ឯកឧត្តមទេសរដ្ឋមន្ត្រីនេះតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ១៩៩៧

**អគ្គរដ្ឋអាជ្ញា**

**ហង់រ៉ូ រ៉ាកេន**

<u>ចម្លងជូន</u>

-ក្រសួងយុត្តិធម៌
-តុលាការកំពូល និងមហាអយ្យការប្រចាំតុលាការកំពូល
-សាលាឧទ្ធរណ៍
-តុលាការខេត្ត.ក្រុង នឹងយោធា
-ដើម្បីជ្រាបជាព័ត៌មាន